# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

## បទពិសោធន៍ជាមួយពិព័រណ៍បែបឌីជីថល មកដល់កម្ពុជាហើយ

ថ្ងៃនេះ ឯកឧត្តម អេនសូនី អាល់បូនីស៊ី នាយករដ្ឋមន្ត្រីអូស្ត្រាលី ដោយមានការចូលរួមពី ឯកឧត្តម លី ធុច ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី១ នៃអាជ្ញាធរមីនកម្ពុជា និងលោក ម៉េតស៊ូ ទ្រីងខា នាយកសារមន្ទីរជាតិអូស្ត្រាលី បានសម្ពោធបើកកម្មវិធីពិព័រណ៍ឌីជីថលបែប 3D ហៅថា ការឈានចូលទៅទស្សនាពិព័រណ៍សងឡាញ (*Walking through a Songline*) នៅហ្សេកធីវី ភ្នំពេញ ដែលជាផ្នែកមួយនៃខួបទី៧០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងអូស្ត្រាលី។

ការឈានចូលទៅទស្សនាពិព័រណ៍សងឡាញ (*Walking through a Songline*) នេះ ជាបទពិសោធន៍ឌីជីថល ដែលជាផ្នែកមួយ នៃការតាំងពិព័រណ៍ដ៏ល្បីថ្នាក់អន្តរជាតិរបស់ សារមន្ទីរជាតិនៃប្រទេសអូស្ត្រាលី ឈ្មោះថា សងឡាញបងប្អូនស្រី៧នាក់ (*Songlines: Tracking the Seven Sisters*)។ Songlines ឬ Dreaming tracks គូសវាសផែនទីផ្លូវរបស់បុព្វបុរស នៅពេលពួកគេធ្វើដំណើរឆ្លងកាត់ប្រទេសអូស្ត្រាលី បង្កើតឡើងបានជាទឹកដី និងប្រជាជន។

អូស្ត្រាលី និងកម្ពុជា ជាប្រទេសដែលមានអ្វីៗជាច្រើន ដោយសារតែប្រទេសយើងទាំងពីរមានសហគមន៍ជនជាតិដើមភាគតិចដ៏រស់រវើក ដែលរួមចំណែកដល់ជីវភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់ប្រទេសយើង។ ការចូលរួមចំណែករបស់ជនជាតិដើមភាគតិច គឺនៅគ្រប់ផ្នែកទាំងអស់ នៃប្រទេសជាតិរបស់យើង មានដូចជា កីឡា នយោបាយ វប្បធម៌ សិល្បៈ បណ្ឌិតសភា អក្សរសាស្ត្រ វិទ្យាសាស្ត្រ តន្ត្រី សុខភាព ដែលជាទ្រព្យសម្បត្តិដ៏សំខាន់បំផុតមួយរបស់យើង។

ពិព័រណ៍នេះ ជាឱកាសមួយសម្រាប់ប្រជាជនអូស្ត្រាលី និងប្រជាជនកម្ពុជាទាំងអស់ ធ្វើការឆ្លុះបញ្ចាំងពីដំណើរដ៏វែងឆ្ងាយនៃទំនាក់ទំនងទ្វេភាគីរបស់យើង ក្នុងរយៈពេល៧០ឆ្នាំចុងក្រោយនេះ ក៏ដូចជាអ្វីដែលយើងអាចធ្វើបានក្នុងរយៈពេល៧០ឆ្នាំខាងមុខ និងរាប់ឆ្នាំទៅមុខទៀត។

*Songlines: Tracking the Seven Sisters* បង្ហាញពី *Songlines* ចំនួនប្រាំ របស់ជនជាតិដើមដំបូង នៅវាលខ្សាច់ខាងលិច និងកណ្តាល របស់ប្រទេសអូស្ត្រាលី។ ពិព័រណ៍នេះ ប្រើប្រាស់គំនូរ និងរូបថត ជាង ៣០០ ផ្ទាំង ព្រមទាំង ឧបករណ៍ ចម្រៀង របាំ និងវីដេអូ ដើម្បីរៀបរាប់អំពីរឿងនិទានពីបងប្អូនស្រីប្រាំពីរនាក់ និងការដែលពួកនាងបានបង្កើតនូវទីបមួយ នៅពេលដែលពួកនាងបានធ្វើដំណើរពីខាងលិចទៅខាងកើត។

ពិព័រណ៍ Walking through a Songline ត្រូវបានផលិតឡើងដោយសារមន្ទីរជាតិអូស្ត្រាលី ក្នុងភាពជាដៃគូជាមួយ Mosster Studio ។ ពិព័រណ៍នេះ ទទួលបានការគាំទ្រជាបន្ត ពីអ្នកថែរក្សាវប្បធម៌ជនជាតិដើម Aboriginal និងជាអ្នកមានចំណេះដឹងទាក់ទងនឹងរឿងនិទាននេះ។

អ្នកទស្សនា អាចចូលទៅកាន់ពិពរណ៍ឌីជីថលពហុញ្ញាណនេះ ហើយពួកគេអាចនឹងមានអារម្មណ៍ ដូចជាមួយនឹងរឿងនិទានជនជាតិដើមបុរាណរបស់អូស្ត្រាលី តាមរយៈបច្ចេកវិទ្យាថ្មីនេះ។

ពិព័រណ៍ឌីជីថលបែប 3D ដែលហៅថា *Walking Through a Songline* នេះ នឹងបើកជាសាធារណៈ ដោយមិនគិតថ្លៃ ចាប់ពីថ្ងៃច័ន្ទ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃអាទិត្យ ទី១១ ខែធ្នូ ឆ្នាំ២០២២ នៅហ្សេកធើរី ភ្នំពេញ ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au